# I ទីស្ដីការគណៈរដ្ឋមន្ត្រី

## ១—អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ២៤ អនក្រ.បក**

**ស្ដីពីការបែងចែកឥណទាន**

**ជំពូក ៥០ ( ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក )**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម.០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស.រកម.១២៩៥.០៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៥ ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាល ស្ដីពីការបែងចែងឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦ ។

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**សំរេច**

**មាត្រា ១** : អនុញ្ញាតិអោយបែងចែកឥណទានជំពូក ៥០.០១ (ឥណទានសាងសង់ និង ទព្វសំភារៈ) ចំនួន ៣០.៦១៥ លានរៀល (សាមសិបពាន់ប្រាំមួយរយដប់ប្រាំលាន -រៀល) និង ជំពូក ៥០.០២ (បតិភាគជារូបិយវត្ថុក្នុងស្រុក នៃហិរញ្ញប្បទានផ្ទាល់ពីបរទេស) ចំនួន ១៣.៣៦០ លានរៀល (ដប់បីពាន់បីរយហុកសិបលានរៀល) ជូនទៅបណ្តាក្រសួង ស្ថាប័ននានាដូចខាងក្រោមនេះ ÷

| លេខកូដ | ក្រសួង ស្ថាប័ន | ជំពូក ៥០.០១ | ជំពូក ៥០.០២ | ផ្សេងៗ |
|---|---|---|---|---|
| ០១ | ព្រះបរមរាជវាំង | ៣.៣៤៩ | | |
| ០២ | រដ្ឋសភា | ៣០០ | | |
| ០៣ | គណៈរដ្ឋមន្ត្រី | ២.៥៤១ | ៦០ | |
| ០៣.១ | ទីស្តីការគណៈរដ្ឋមន្ត្រីផ្ទាល់ | ២.៥៤១ | | |
| ០៣.២ | អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា | | ៦០ | |
| ០៤ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១៣២ | | |
| ០៦ | ក្រសួងមហាផ្ទៃ | ៥៥៣ | ៣.៥០៣ | |
| ០៦.១ | រដ្ឋបាលទូទៅ | ៥៥៣ | - | |
| ០៦.៩ | ខេត្ត-ក្រុងនានា | | ៣.៥០៣ | សំរាប់ផ្លូវទឹកភ្នំពេញ |
| ០៧ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ៥.១៧០ | ២.០០៩ | សំរាប់ត្រៀមបែងចែក |
| ០៨ | ក្រសួងពត៌មាន | ២៥០ | | |
| ០៩ | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ១០.៦៦០ | ២.៣២៧ | |
| ១០ | ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ | | ៣៦៤ | |
| ១១ | ក្រសួងយុត្តិធម៌ | ២៥០ | | |
| ១៣ | ក្រសួងពាណិជ្ជកម្ម | ៦០ | | |

| | | | | |
|---|---|---|---|---|
| ១៤ | ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | ២១៤ | ៤.៩៣២ | |
| ១៥ | ក្រសួងផែនការ | ៤០០ | | |
| ១៧ | ក្រសួងទេសចរណ៍ | ៣០០ | | |
| ១៨ | ក្រសួងធម្មការ និង កិច្ចការសាសនា | ៦៦៩ | | |
| ១៩ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ២៩៩ | | |
| ២០ | ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | | ១៥ | |
| ២១ | ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន | ១.៧៩៨ | | |
| ២២ | ក្រសួងបរិស្ថាន | ៣០៥ | | |
| ២៣ | ក្រសួងអភិវឌ្ឍន៍ជនបទ | ៣.០១៥ | ១៥០ | |
| ២៤ | ក្រសួងកិច្ចការនារី | ៣៥០ | | |
| | សរុប | ៣០.៦១៥ | ១៣.៣៦០ | |

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី នៃក្រសួងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះ ហស្តលេខា និង ចុះហត្ថលេខានេះតទៅ ÷

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឬទ្ធិ** | **ហ៊ុន សែន** |

* * *